*ហូល*

1. *(សំលៀកបំពាក់) ( ន. ) ឈ្មោះសំពត់សូត្ររបស់ខ្មែរ ត្បាញដោយសូត្រចងគាធលើកជាគោមជាក្រឡាក្បាច់រចនាវិចិត្រផ្សេងៗ តាមចំពោះនិងសេចក្ដីពេញចិត្តនៃអ្នកត្បាញ, ជាការយ៉ាងល្អិតធ្វើដោយផ្ចិតផ្ចង់មមីះមមៀវរបស់ស្ត្រីខ្មែរ : ហូលប្រុស, ហូលស្រី ។ ប្រភេទសំពត់ត្បាញពីសរសៃសូត្រ ដោយចងគាធលើកគោមតូចឬធំ រចនាជារូបភាពតាមធម្មជាតិច្រើនបែបយ៉ាង។ សំពត់ហូលសម្រាប់ស្ត្រីមានគោមតូចៗដូចជា រូបផ្កាម្ទេស ផ្កាទទឹម សត្វពីងពាង សត្វអណ្ដើកជាដើម។ សម្រាប់បុរសស្លៀក គេលើកគោមធំៗមាន រូបសត្វដំរី សត្វនាគ សត្វហង្ស សត្វគ្រុឌ។ ហូលជរ ហូលដែលត្បាញលើកជាក្បាច់ជរត្រង់ជាយ ។ ព. កា. ថា : មេបាស្លៀកហូលជរ សម្ដីខ្ជរប្រកាន់ច្បាប់ ឲ្យត្រូវតាមទម្លាប់ សណ្ដាប់ធ្នាប់ទម្រង់ការ ។ ពីបូរាណព្រេងព្រឹទ្ធ ត្រូវតែគិតតាមវោហារ ចាស់ទុំជារអាចារ្យ ទើបកិច្ចការបានចម្រើន ។*

*ផាមួង*

1. *ស. ( ន. ) ឈ្មោះសំពត់សូត្រមួយប្រភេទមានព័ណ៌លាតផ្សេងៗសម្រាប់ស្លៀក, កំណើតធ្វើក្នុងកម្ពុជរដ្ឋ : ផាមួងព័ណ៌ព្រីងទុំ, ផាមួងព័ណ៌ស្លាទុំ ។ ប្រភេទសំពត់ត្បាញពីសរសៃសូត្រ មានសាច់លាត និង ពណ៌ផ្សេងៗ ជូនមានបន្តក់ជរជើងនិងមានបន្តក់លើផ្ទៃសំពត់។ សំពត់ដែលមានបន្តក់ឬជរជើងត្បាញពីអំបោះសម្រាប់ស្លៀកពេលថ្ងៃ។ ចំណែកសំពត់ដែលមានបន្តក់ឬជរជើងត្បាញពីខ្សែពណ៌ទឹកមាស ឬទឹកប្រាក់មានពន្លឺចែងចាំង សម្រាប់ស្លៀកនៅពេលយប់។*

*ស៊ឹង*

1. *(សំលៀក) ប្រភេទសំពត់ត្បាញពីអំបោះ មានក្បាច់ឬឆ្នូតទទឹងនៅតាមជាយស្រដៀងគ្នានឹងស៊ឹងលាវ ប៉ុន្តែស៊ឹងលាវខុសគ្នាត្រង់មានដេរបន្ថែមជរនៅជើងសំពត់។ សំពត់នេះ ខ្មែរប្រើក្នុងជីវភាពរស់នៅធម្មតាឬក្នុងការសម្តែងរបាំគែន និងរបាំក្រោកប៉ៃលិន...។ គេឃើញមានសិប្បកម្មត្បាញសំពត់ស៊ឹងតែនៅតំបន់ព្រៃកប្បួងទេ ក្នុងទស្សវត្សរ៍ទី៦ និង ទី៧ សតវត្សរ៍ទី២០។*

*សារុង*

*--រ៉ុង ( ន. ) សំពត់អំបោះឬសូត្រ ត្បាញចាក់ជាក្រឡាឆ្លាស់ព័ណ៌ ឬធ្វើជាផ្កា ជាគំនូរ រំលេចព័ណ៌សម្រាប់ភ្នើញស្លៀកសម្លុយ, ជាសម្លៀករបស់ចាមជ្វាជាដើម : សារុងអំបោះ, សារុងសូត្រ ។ សារុងដែលខ្មែរប្រើមាន ២ ប្រភេទគឺ សារុងស្រី, សារុងប្រុស; សារុងសម្រាប់ស្រីៗសុទ្ធតែមកពីបរទេស, ស្រីៗអាចប្រើជាប្រក្រតីបាន មិនទាស់ទំនងរបស់សុជីវធម៌ខ្មែរទេ, ឯសារុងសម្រាប់ប្រុសៗ ច្រើនតែត្បាញក្នុងប្រទេសកម្ពុជា, ប្រុសៗស្លៀកបានចំពោះតែក្នុងផ្ទះលំនៅ ក្នុងពេលដែលយល់ថាគួរស្លៀកបាន, ពុំអាចស្លៀកដើរចេញទៅខាងក្រៅផ្ទះលំនៅឡើយ (នេះជាសុជីវធម៌ដ៏សមរម្យរបស់ខ្មែរ) ។*

***វិគីនានុក្រម***

https://km.wiktionary.org/wiki/